មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

# របាយការណ៍ស្តីពី
# ស្ត្រីនៅក្នុង ស្រុកអន្លង់វែង



លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង



*ប៊ុន សុកុល អតីតនារីពេទ្យក្នុងសម័យខ្មែរក្រហម ឈរក្បែរឪពុកឈ្មោះ កឿក ប៊ុនធឿន ដែលជាអតីតគ្រូបង្រៀន ក្នុងសម័យសង្គមរាស្ត្រនិយម។*



# សេចក្តីថ្លែងអំណរគុណ

របាយការណ៍ស្តីពីជីវភាពប្រចាំថ្ងៃនិងកិច្ចការដែលស្រ្តីនៅអន្លង់វែងបានបំពេញ ក្នុងអំឡុងពេលនៃការធ្វើសង្គ្រាមទ័ពព្រៃរបស់ចលនាខ្មែរក្រហមនៅចន្លោះឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៩៨ នឹងមិនអាចធ្វើទៅបានទេ ប្រសិនបើមិនមានការគាំទ្រ និងការសហការល្អរបស់ស្រ្តីទាំងឡាយ ដែលបានរស់ឆ្លងកាត់រយៈកាលនោះ។ ការថ្លែងអំណរគុណរបស់ខ្ញុំក៏សូមផ្ញើជូនស្រ្តីទាំងឡាយនៅក្នុងស្រុកអន្លង់វែងដែរ ដោយសារស្រ្តីភាគច្រើនបានចូលរួមក្នុងវេទិកាលើកកម្ពស់សិទ្ធិស្រ្តី ដែលរៀបចំឡើងជារៀងរាល់ខែ ដោយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។

ខ្ញុំក៏សូមថ្លែងអំណរគុណដល់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា សម្រាប់ការណែនាំនិងគាំទ្រឲ្យមានការចងក្រងរបាយការណ៍នេះ។ ខ្ញុំក៏សូមអរគុណដល់បណ្ឌិត Markus Zimmer ដែលជាទីប្រឹក្សាជាន់ខ្ពស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា សម្រាប់ការអាន និងពិនិត្យមើលរបាយការណ៍នេះ។ ខ្ញុំក៏សូមអរគុណដល់សហការីរបស់ខ្ញុំនៅក្នុងស្រុកអន្លង់វែងសម្រាប់ការ សម្របសម្រួល និងការធ្វើបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មាន។ ខ្ញុំក៏សូមអរគុណ ដល់កញ្ញា ជេនីហ្វើរ ហូវ៉េ អ្នកស្រាវជ្រាវថ្នាក់បណ្ឌិតផ្នែកសិក្សាអំពីសង្គ្រាម នៃសាកលវិទ្យាល័យឃីងខូលេក ទីក្រុង ឡុងដ៍ ( King's College London ) ដែលបានអាន និងកែសម្រួលសំណេរនេះ។



*គីម ស្រ៊ី នៅវាលជងទង់ ក្នុងឆ្នាំ១៩៨៨។*

# សេចក្តីផ្តើម

នៅក្នុងអំឡុងរបបខ្មែរក្រហម(១៩៧៥-១៩៧៩) សង្គ្រាមនិងអំពើប្រល័យពូជសាសន៍បានធ្វើឲ្យបុរសនិងស្ត្រីទទួលភារកិច្ចយ៉ាងស្មើភាពគ្នា។ ស្ត្រីនិងបុរសត្រូវឡើងទៅសមរភូមិ ផ្តល់ការគាំទ្រដល់សមរភូមិ និងតស៊ូជម្នះដើម្បីការរស់រានមានជីវិតជាដើម។ ស្ត្រីជាច្រើនត្រូវបានដាក់ឲ្យស្ថិតនៅក្នុងការទទួលខុសត្រូវសំខាន់ៗទៀតផង។ តែផ្ទុយទៅវិញ ភារកិច្ចនិងសកម្មភាពទាំងឡាយរបស់ស្ត្រីត្រូវបានថមថយទៅវិញក្នុងអំឡុងពេលសុខសាន្តត្រាណ។ សូម្បីតែសព្វថ្ងៃនេះ នៅក្នុងករណីខ្លះ ស្ត្រីត្រូវបានផាត់ចេញពីដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តនានា នៅក្នុងក្រុមគ្រួសារនិងក្នុងវិស័យនយោបាយនៅថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិ។ ពេលខ្លះ ស្ត្រីជាច្រើនយល់ឃើញថាដំណើរការទាំងអស់នោះគួរតែមានភាពសមស្របជាមួយសមត្ថភាពនិងចំណេះដឹងរបស់ខ្លួនក្នុងការទទួលបានតួនាទីនិងមានការទទួលខុសត្រូវក្នុងវិស័យគ្រប់គ្រង និងអង្គភាពសាជីវកម្មផ្សេងៗដែរ។

ក្នុងអំឡុងរបបប្រល័យពូជសាសន៍ បុរសនិងស្ត្រីមានតួនាទីប្រហាក់ប្រហែលគ្នា និងតស៊ូលះបង់ដើម្បីបដិវត្តន៍។ អន្លង់វែង ដែលធ្លាប់ជាតំបន់តស៊ូចុងក្រោយនៃចលនាខ្មែរក្រហមហើយខ្មែរក្រហមបានគ្រប់គ្រងតំបន់នេះរហូតដល់ឆ្នាំ១៩៩៨ គឺជាឧទាហរណ៍ដ៏ល្អមួយដើម្បីបង្ហាញអំពីតួនាទីសកម្មរបស់ស្ត្រីនៅក្នុងជម្លោះនោះ។ ស្ត្រីគឺជាឆ្អឹងខ្នងនៃការតស៊ូប្រដាប់អាវុធរយៈពេលយូររបស់ខ្មែរក្រហមនៅទីនោះ ចាប់ពីឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ១៩៩៨។ ស្ត្រីគឺជាអ្នកគាំទ្រឥតងាករេ ដែលធ្វើឲ្យមានតុល្យភាពកម្លាំងនៅ សមរភូមិមុខ និងសមរភូមិក្រោយ។ ស្ត្រីបានចូលរួមយ៉ាងសកម្មនៅតាមបណ្តាអង្គភាពពេទ្យនិងកងដឹកជញ្ជូន។ ស្ត្រីភាគច្រើនបំផុតទទួលបន្ទុកលើការធានាឲ្យមានការរស់រានមានជីវិតរបស់ក្រុមគ្រួសារ។ ការទទួលខុសត្រូវរបស់ស្ត្រីទាំងនោះរាប់បញ្ចូលទាំងការបង្កបង្កើនផលប្រចាំឆ្នាំដើម្បីផ្គត់ផ្គង់អាហារ ការចិញ្ចឹមបីបាច់និងអប់រំកូន ជានាឲ្យបាននូវសហគមន៍ដ៏រឹងមាំ មានភាពប្រយ័ត្នប្រយែងចំពោះការវាយប្រហាររបស់កងទ័ពជាយថាហេតុ និងបិតចម្រូងដើម្បីការពារសមរភូមិនិងសហគមន៍របស់ខ្លួនទៀតផង។

រយៈពេលច្រើនឆ្នាំនៅក្នុងសមរភូមិយ៉ាងក្តៅគគុកបានបញ្ចប់ទាំងស្រុង នៅពេលដែលកងកម្លាំងខ្មែរក្រហមដែលនៅសេសសល់នៅអន្លង់វែងបានធ្វើសមាហរណកម្មមកក្នុងរាជរដ្ឋាភិបាលកម្ពុជា នាឆ្នាំ១៩៩៨។ នៅក្នុងសតវត្សរ៍ទី២១នេះ សហគមន៍នេះបានវិលត្រឡប់មករកប្រក្រតីភាពឡើងវិញ ហើយប្រឹងប្រែងយ៉ាងខ្លាំងក្លាដើម្បីប្រែក្លាយអតីតតំបន់តស៊ូចុងក្រោយរបស់ខ្មែរក្រហមឲ្យទៅជាទីក្រុងសន្តិភាព។ ការថែរក្សាប្រវត្តិសាស្ត្រខ្មែរក្រហមនិងការចងចាំរបស់អតីតជនបដិវត្តន៍និងសមាជិកខ្មែរក្រហមគឺជាគន្លឹះក្នុងការចាប់ផ្តើមឲ្យមានភាពបំរែបំរួលនេះ។ ក្នុងចំណោមអតីតសមាជិកខ្មែរក្រហមចំនួន៨០ភាគរយនៅក្នុងស្រុកអន្លង់វែងនេះ ស្ត្រីមានចំនួនប្រមាណជា២០ភាគរយ។ ស្ត្រីបានជួយទ្រទ្រង់កម្លាំងខ្មែរក្រហម និងបានចូលរួមយ៉ាងសកម្មនៅក្នុងសង្គ្រាមនោះ។ ស្ត្រីភាគច្រើនបំផុតបានចូលរួមក្នុងចលនាបដិវត្តន៍ខ្មែរក្រហមក្នុង

វ័យក្មេងនៅឡើយ ហើយបានស៊ូទ្រាំចំពោះឧបសគ្គនិងភាពអស់សង្ឃឹមដែលមិនអាចរៀបរាប់អស់ នៅមុនពេលនិងក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់ខ្មែរក្រហម(១៩៧៥-១៩៧៩)។ រយៈកាលនៅក្រោយរបបខ្មែរក្រហម បានជំរុញឲ្យស្ត្រីជាច្រើនស្ម័គ្រចិត្តចូលរួមក្នុងការតស៊ូប្រដាប់អាវុធរបស់កងកម្លាំងខ្មែរក្រហមប្រឆាំងនឹងរដ្ឋាភិបាលកម្ពុជា ឬត្រូវបានបង្ខំឲ្យស្ថិតក្នុងស្ថានភាពដែលស្ត្រីទាំងនោះមិនអាចត្រឡប់ទៅរកជីវិតរស់នៅធម្មតាបានឡើយ។

ដូចដែលប្រវត្តិសាស្ត្រខ្មែរក្រហមត្រូវបានចងក្រង អំពើឃោរឃៅរបស់របបនេះបានបង្កឲ្យមានការប៉ះពាល់យ៉ាងធំធេងទៅលើស្ត្រី និងប្រជាជនកម្ពុជាទូទៅ។ ជាការពិតណាស់ ស្ត្រីគឺជាផ្នែកមួយដ៏សំខាន់ក្នុងហេតុការណ៍វិវឌ្ឍន៍របស់សង្គមនិងនយោបាយនៅក្នុងប្រវត្តិសាស្ត្រថ្មីៗរបស់ប្រទេសកម្ពុជាស្តីពីអំពើប្រល័យពូជសាសន៍ សង្គ្រាម ការស្តារឡើងវិញ និងសន្តិភាព។ ជារឿយៗ ដោយហេតុថាការរើសអើងជាទម្លាប់ទាក់ទងនឹងថាតើសង្គមនោះត្រូវបានរៀបចំឡើងយ៉ាងដូចម្តេច ហើយតួនាទីខុសៗគ្នារបស់បុរសនិងស្ត្រី ភាគច្រើននៃស្ត្រីត្រូវបានដាក់ឲ្យស្ថិតនៅក្នុងតួនាទីបន្ទាប់បន្សំ ដែលហាក់ដូចជាមើលរំលងសក្តានុពលរបស់ស្ត្រីក្នុងការដើរតួនាទីស្មើភាពគ្នា និងរួមចំណែកស្មើគ្នានៅក្នុងសង្គម ជាពិសេសក្នុងពេលបច្ចុប្បន្ន។

ដោយសារតែកត្តានេះហើយ ទើបរបាយការណ៍នេះព្យាយាមផ្តោតលើការចូលរួមកាលពីដើមដំបូងៗរបស់ស្ត្រីនៅក្នុងចលនាបដិវត្តន៍ ការឈានចូលក្នុងរបបគ្រប់គ្រងរបស់ខ្មែរក្រហមដែលមិនអាចបកក្រោយបាន (១៩៧៥-១៩៧៩) និងការធានាបាននូវអត្ថិភាពរបស់ខ្លួននៅសមរភូមិក្រោយ។ ផ្នែកចុងក្រោយនៃរបាយការណ៍នេះព្យាយាមផ្តល់ជូននូវអនុសាសន៍មួយចំនួនដើម្បីធ្វើឲ្យប្រសើរឡើងនូវសិទ្ធិ ឱកាស និងឋានៈក្នុងសង្គមនយោបាយជាដើម។




ឃី ធា

# មាគ៌ាដំបូងឆ្ពោះ
# ទៅកាន់បដិវត្តន៍ខ្មែរក្រហម



ឃុយ គា

ស្ត្រីទាំងឡាយដែលបានផ្តល់ការសម្ភាសន៍នៅក្នុងស្រុកអន្លង់វែង បានមើលឃើញថាខ្លួនស្ថិតក្នុងភាពត្រដាបត្រដួស ខណៈដែលខ្មែរក្រហមបានរុញច្រានប្រទេសឲ្យធ្លាក់ក្នុងសង្គ្រាម កាលពីដើមទសវត្សរ៍ឆ្នាំ១៩៧០។ ដូចស្ថានភាពរបស់យុវនារីវ័យជំទង់ក្រីក្រនៅតាមបណ្តាតំបន់ជនបទនៃប្រទេសកម្ពុជាទៀតដែរ ស្ត្រីទាំងនោះមិនបានត្រៀមខ្លួនសម្រាប់ការកេណ្ឌឲ្យចូលបម្រើក្នុងជួរកងទ័ពរបស់ខ្មែរក្រហមឡើយ បន្ទាប់ពីរដ្ឋប្រហារទម្លាក់របបសង្គមរាស្ត្រនិយមរបស់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ ស្ត្រីភាគច្រើនបានចាកចេញពីឪពុកម្តាយរបស់ខ្លួននិងត្រូវបានបង្ខំឲ្យលះបង់ដើម្បីបម្រើបដិវត្តន៍។ សាញ់ សុគន្ធ វ័យ៦៣ឆ្នាំ ឆែម ឡៃ វ័យ៥៧ឆ្នាំ និង ឃុយ គា វ័យ៦០ឆ្នាំ បាននិយាយដាច់ដោយឡែកពីគ្នាថា ខ្លួនបានចូលរួមជាមួយខ្មែរក្រហមនៅក្នុងវ័យជាង១០ឆ្នាំ ខណៈដែលប្រជាជនកម្ពុជាភាគច្រើនបានមើលឃើញផ្កាយដុះកន្ទុយធ្លាក់ចុះមក ហើយយើងជឿថា ប្រទេសជាតិនឹងកើតកលិយុគ អស្ថិរភាពសង្គម ឬ

សង្គ្រាម។ គា បាននិយាយថា បន្ទាប់ពីរដ្ឋប្រហារ គាត់និងបងប្អូនប្រុសៗពីរនាក់ទៀតបានចាប់ផ្តើមចូលបម្រើក្នុងជួរកងទ័ព។ បើប្រៀបធៀបជាមួយ គា វិញ ឡៃនិងសមាជិកក្រុមគ្រួសារចំនួន១៧នាក់បានភៀសខ្លួនចូលព្រៃហើយចាប់ផ្តើមជីវិតនៅក្នុងព្រៃចាប់ពីពេលនោះមក។

ក្នុងវ័យប្រហាក់ប្រហែលគ្នានេះដែរ សាញ់ សុគន្ធ ស្ម័គ្រចិត្តចូលបម្រើជាទាហានខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៤។ ខ្មែរក្រហមក៏បានបញ្ចូលគាត់និងស្ត្រីមួយចំនួនទៀតទៅក្នុងក្រុមសម្តែងសិល្បៈ។ ក្រោយមក សុគន្ធ ត្រូវបានបណ្តុះបណ្តាលឲ្យទៅជាគ្រូបណ្តុះបណ្តាលសិល្បៈ។ ក្នុងរយៈពេល៦ខែក្រោយមក ភារកិច្ចរបស់ខ្លួនបានផ្លាស់ប្តូរ ហើយខ្លួនក៏ត្រូវបានតម្រូវឲ្យបម្រើក្នុងជួរកងទ័ព ពេទ្យទាហាន និងអ្នកបណ្តុះបណ្តាលកងទ័ពជូនដល់បុរសនិងស្ត្រីដែលទើបជ្រើសរើសថ្មីៗរាប់រយនាក់។ សុគន្ធ ក៏ត្រូវបានបញ្ជូនទៅកាន់សមរភូមិមុខនៅភ្នំបាសិតនៅក្នុងខែមករា ឆ្នាំ១៩៧៥ ដែលជាជំហានចុងក្រោយរបស់ខ្មែរក្រហមក្នុងការវាយដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ។ សុគន្ធ ឡៃ និងគា បានឆ្លងកាត់បទពិសោធន៍ និងតស៊ូជម្នះនូវដំណាក់កាលជាច្រើននៃភាពភ័យខ្លាច ភាពភ័យស្លន់ស្លោ និងភាពរំជួលចិត្តដើម្បីបានរស់រានមានជីវិតពីរយៈកាលនោះ ដែលជាកម្រិតនៃភាពតានតឹងផ្លូវចិត្តដែលយុវនារីវ័យជំទង់ទាំងឡាយមិនទាន់អាចបេះរិះគិតនិងដោះស្រាយឲ្យបានស្រួលបួលនៅឡើយ។



សាញ់ សុគន្ធ

ការចូលរួមពីដើមដំបូងរបស់ស្ត្រីទាំងអស់នេះក្នុងចលនាបដិវត្តន៍ខ្មែរក្រហមបានរួមចំណែកយ៉ាងធំធេងដល់ជ័យជម្នះរបស់ខ្មែរក្រហមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ការចូលបម្រើកងទ័ពក្នុងវ័យក្មេងបែបនេះបានជម្នះការរំពឹងរបស់ប្រជាជនកម្ពុជាទូទៅដែលថាស្ត្រីវ័យក្មេងៗមិនគួរចាកឆ្ងាយពីផ្ទះសម្បែងនិងឪពុកម្តាយ។ តែទោះបីជា យ៉ាងណា ជ័យជម្នះរបស់ខ្មែរក្រហមមិនមានន័យថា ស្ត្រីទាំងនោះបានទទួលសេរីភាពក្នុងការធ្វើអ្វីតាមការប្រាថ្នានោះដែរ។ ដំណាក់កាលដំបូងនេះគឺគ្រាន់តែជាការចាប់ផ្តើមនូវអ្វីដែលនាំទៅដល់រយៈកាលដ៏អន្ធការបំផុតក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាតែប៉ុណ្ណោះ។

# ការឈានចូលក្នុងរយៈកាលនៃ របបប្រល័យពូជសាសន៍



អ៊ួន ណាម

ស្ត្រីទាំងអស់នេះបានចាប់ផ្តើមបំពេញភារកិច្ចរបស់ខ្លួន ដោយមានការបំពាក់បំប៉នមនោគមវិជ្ជាឲ្យជឿថា ខ្លួនគឺជាអ្នករំដោះប្រទេសប្រកបដោយភាពសប្បាយរីករាយ។ បន្ទាប់មក ស្ត្រីក៏ទទួលបានការបំពាក់បំប៉នបន្ថែមទៀតឲ្យអនុវត្តនូវរបៀបរបបសង្គមថ្មីដែលកើតឡើងបន្ទាប់ពីជ័យជម្នះរបស់ខ្មែរក្រហម។ តាមពិតទៅ ជីវិតរបស់ស្ត្រីវ័យក្មេង បានទទួលរងនូវការដកហូតសិទ្ធិយ៉ាងធ្ងន់ធ្ងរនិងទទួលរងនូវភាពឯកោ។ ការជួបជុំក្រុមគ្រួសារឡើងវិញមិនត្រូវបានអនុញ្ញាតឡើយ។ ប្រជាជនត្រូវបានជម្លៀសចេញពីលំនៅឋានរបស់ខ្លួន។ គ្រោះទុរ្ភិក្សបានប៉ះពាល់ដល់មនុស្សគ្រប់ៗគ្នាទាំងអស់។ ការសម្លាប់ត្រូវបានធ្វើឡើងជាប្រព័ន្ធ។ សិទ្ធិនិងសេរីភាពសំខាន់ៗទាំងអស់ត្រូវបានដកហូតទាំងស្រុង។ ចំពោះស្ត្រី និងប្រជាជនដទៃទៀត នេះគឺជាដំណើរឆ្ពោះទៅកាន់ជម្រៅនៃនរកលោកិយមួយដែលមិនអាចបកក្រោយបាន។

សុគន្ធ ធ្លាប់បម្រើការជាកងទ័ពខ្មែរក្រហមមួយរូបដែរ ដែលបានចូលទៅក្នុងទីក្រុងភ្នំពេញ។ សុគន្ធបានឮអ្នកនៅទីក្រុងជាច្រើនបាននិយាយថា៖ « ខ្មែរក្រហមធ្លាប់រស់នៅក្នុងព្រៃ ប៉ុន្តែពួកខ្មែរក្រហមស្អាតៗ ហើយមានម៉ូដសក់ស្អាតៗនៅត្រឹមស្មាទៀត»។ សុគន្ធ ក៏បានចងចាំដែរថា ប្រជាជនជាច្រើនមិនហ៊ានចេញពីផ្ទះរបស់ខ្លួនទេ ដោយប្រជាជនទាំងអស់នោះ ខ្លាចខ្មែរក្រហមអារកនឹងជាងត្នោត។ ខណៈដែល សុគន្ធ

និងសមាជិកក្រុមរបស់ខ្លួនចំនួន២៥នាក់បោសសម្អាតទីក្រុង គាត់បានឃើញផ្ទាល់ភ្នែកនូវហ្វូងមនុស្សយ៉ាងកកកុញដែលត្រូវបានជម្លៀសចេញពីទីក្រុង។ ពាក្យពេចន៍របស់គាត់មួយចំនួនទៅកាន់អ្នកជម្លៀសទាំងអស់នោះថាឲ្យវេចខ្ចប់ម្ហូបអាហារ និងអំបិលជាដើម ខណៈដែលភូមិភាគគ្រប់គ្រងដោយខ្មែរក្រហមនោះមិនចាយលុយទេ។ ខណៈដែលកងកម្លាំងខ្មែរក្រហមជាច្រើនបានចូលទៅក្នុងទីក្រុងភ្នំពេញ សុគន្ធ បានគិតថា អ្នកជម្លៀសទាំងអស់នោះ អាចគិតថា កម្មាភិបាលខ្មែរក្រហមដូចជារូបគាត់ គឺហាក់មានសំណាងជាងអ្នកជម្លៀស។ ប៉ុន្តែតាមពិតទៅ វាមិនពិតនោះទេ។ កងកម្លាំងខ្មែរក្រហម ជាពិសេសស្ត្រីៗ បានជួបប្រទះនូវបញ្ហាប្រឈមដែលមិនអាចជម្នះបាននៅក្នុងអំឡុងរបបខ្មែរក្រហម។ សម្រាប់ សុគន្ធ គាត់ត្រូវបានបញ្ជូនពីកន្លែងមួយទៅកាន់កន្លែងមួយទៀតដើម្បីជាកម្លាំងស្រួចរបស់បដិវត្តន៍ខ្មែរក្រហម។ ដូចអ្នកផ្សេងៗទៀតដែរ ការងាររបស់គាត់រួមមាន ការកសាងទំនប់ ការផលិតស្លុកត្នោត ការដាំស្រូវ និងភារកិច្ចផ្សេងៗទៀត។ ក្រោយមក សុគន្ធ ត្រូវបានចាត់ឲ្យទៅធ្វើការនៅឯការដ្ឋានសាងសង់ព្រលានយន្តហោះនៅស្រុកកោះញែក ខេត្តមណ្ឌលគិរី។ ការងារទាំងនោះ បានធ្វើឲ្យគាត់និងអ្នកផ្សេងៗទៀតអត់អាហារ ល្វិតល្វៃ ហើយប៉ះពាល់ដល់ផ្លូវចិត្តជាខ្លាំង។

ការសម្លាប់មនុស្សជាច្រើនដោយរាប់បញ្ចូលទាំងកម្មាភិបាលរបស់ខ្លួនឯងផងនោះ មានលក្ខណៈរាលដាល។ ក្នុងនាមជាប្រធានភូមិស្ត្រីម្នាក់ដែរ ឆែម ឡៃ មិនស្ទាក់ស្ទើរក្នុងការនិយាយថា ការសម្លាប់មិនរើសមុខបានកើតឡើងនៅក្នុងរបបនោះ។ ឡៃ បាននិយាយថា៖ «ខ្ញុំបានឃើញផ្ទាល់ភ្នែកនូវការសម្លាប់មនុស្ស។ ជនរងគ្រោះត្រូវបានដឹកតាមរទេះ ហើយរណ្តៅត្រូវបានជីករួចជាស្រេច។ ជនរងគ្រោះនីមួយៗត្រូវបានវាយនឹងដែកភ្លៅរទេះចំពីខាងក្រោយក្បាល ហើយធ្លាក់ចូលទៅក្នុងរណ្តៅ។ ខ្ញុំមានអារម្មណ៍ភ័យខ្លាចជាខ្លាំង។ សម្រាប់យើងគ្មានឱកាសជួយអ្នកទាំងអស់នោះបានទេ។ បើមិនដូច្នោះទេ យើងក៏ត្រូវបានសម្លាប់ដែរ»។ គឹមលី អាយុ៦៥ឆ្នាំ ក៏ស្ថិតក្នុងចំណោមមនុស្សរាប់លាននាក់ដែលបានបាត់បង់សាច់ញាតិនៅក្នុងជំនាន់នោះដែរ។ បន្ទាប់ពី គឹមលី បានសម្រាលកូនរបស់ខ្លួននៅក្នុងឆ្នាំ១៩៧៦ ប្តីរបស់គាត់ត្រូវបានយកទៅសម្លាប់ដោយចោទថាជានាយទុន និងសក្តិភូមិ។ គឹមលី បានបន្ថែមទៀតថា សាច់ថ្លៃរបស់គាត់ម្នាក់មានការទទួលខុសត្រូវចំពោះការស្លាប់ប្តីរបស់គាត់។ ចំណែកកូនរបស់គាត់ ក្រោយមកក៏បានស្លាប់ដោយសារការអត់អាហារដែរ។

បើទោះបីជាមានបទពិសោធន៍ប្រកបដោយសោកនាដកម្មនេះក៏ដោយ ខ្មែរក្រហមបានខិតខំរិះរកមធ្យោបាយដកថយតាមយុទ្ធសាស្ត្ររបស់ខ្លួន ហើយបាននាំយកជនបដិវត្តន៍ជាច្រើន និងប្រជាជនទៅជាមួយដែរ នៅពេលដែលកងទ័ពវៀតណាមបានវាយបណ្តេញរបបខ្មែរក្រហមចេញពីអំណាចនៅក្នុងខែមករា ឆ្នាំ១៩៧៩។ បើយោងតាម ឃុយ គា ហេតុផលមួយក្នុងចំណោមហេតុផលជាច្រើនដែលប្រជាជនបានជម្លៀសទៅជាមួយខ្មែរក្រហម គឺដោយសារតែខ្លាចវៀតណាម។ មានពាក្យចចាមអារ៉ាមថា វៀតណាមនឹងសម្លាប់ចោល ខណៈដែលកងទ័ពវៀតណាមបានព្យាយាមវាយបណ្តេញខ្មែរក្រហមចេញពីអំណាចនោះ។ ខ្មែរក្រហមមានលទ្ធភាពរៀបចំក្រុមឡើងវិញ ហើយធ្វើសង្គ្រាមទ័ពព្រៃអស់រយៈពេលពីរទសវត្សរ៍បន្ថែមទៀត។ ខណៈដែលកងកម្លាំងរបស់ខ្លួនត្រូវបានបញ្ជូនទៅធ្វើប្រតិបត្តិការនៅតាមតំបន់ជនបទឆ្ងាយៗ ស្ត្រីក៏ទទួលបន្ទុកយ៉ាងធំធេងក្នុងការជួយគាំទ្រដល់សមរភូមិមុខដែរ និងធានាឲ្យបានសម្រាប់សមរភូមិក្រោយប្រកបដោយភាពរឹងមាំក្នុងអំឡុងរយៈពេលពីរទសវត្សរ៍នៃសង្គ្រាម។ ដូច្នេះហើយរបាយការណ៍នេះ យល់ឃើញថា មានសារសំខាន់ក្នុងការពិនិត្យមើលពីតួនាទីរបស់ស្ត្រីនៅឯសមរភូមិក្រោយដែលធានាបាននូវភាពធន់សម្រាប់សមរភូមិមុខដែរ។

# ការធានាឲ្យបាននូវនិរន្តរភាព នៅឯសមរភូមិក្រោយ

ស្ត្រីទាំងឡាយនៅតាមបណ្តាភូមិ ឬតំបន់ដែលគ្រប់គ្រងដោយខ្មែរក្រហមនៅតាមបណ្តោយព្រំដែនថៃ មានការទទួលខុសត្រូវក្នុងការធានាឲ្យបាននូវនិរន្តរភាពសម្រាប់សមរភូមិ។ នៅពេលដែលរបបខ្មែរក្រហមត្រូវបានបណ្តេញចេញពីអំណាច កម្មាភិបាលរបស់ខ្លួនគ្រប់លំដាប់ថ្នាក់បានជម្លៀសទៅកាន់ព្រំដែន ហើយស្ត្រីជាច្រើនបានស្ថិតនៅក្នុងចំណោមមនុស្សដែលត្រូវបានជម្លៀសនោះដែរ។ ស្ត្រីត្រូវបានធ្វើដំណើរឆ្លងកាត់តំបន់ព្រៃដ៏គ្រោះថ្នាក់ដែលមិនអាចពិពណ៌នាបាន ប្រឈមប្រថាននឹងការវាយប្រហារ និងតាំងទីលំនៅតាមតំបន់គ្រោះថ្នាក់ និងមិនមានសុវត្ថិភាពជាច្រើនទៀតផង។ យុយ គា ដែលមានវ័យ៦៥ឆ្នាំ, ជិន សេង ដែលមានវ័យ៦៦ឆ្នាំ, អ៊ិន ខុម និងអ៊ួន ណម គឺស្ថិតក្នុងចំណោមស្ត្រីដែលត្រូវបានសម្ភាសន៍នេះដែរ។ ស្ត្រីទាំងអស់នេះ បានរៀបរាប់ថា ខណៈដែលកងទ័ពវៀតណាមកាន់តែចូលមកជិតយើង មានពាក្យចចាមអារ៉ាមជាច្រើនបានលេចឮថា កងទ័ពវៀតណាមបានសម្លាប់មនុស្សចោលទាំងអស់។ ស្ត្រីទាំងអស់នោះក៏បានចាប់ផ្តើមភៀសខ្លួន និងរស់នៅតាមមូលដ្ឋានរបស់ខ្មែរក្រហម។ ភាពភ័យខ្លាចចំពោះវៀតណាមបានធ្វើឲ្យអ្នកទាំងអស់រួមគ្នា ហើយជំរុញឲ្យខ្លួនសហការគ្នានៅឯសមរភូមិក្រោយអស់រយៈពេលជាច្រើនឆ្នាំមកទៀត។



យឹម ផល

ដូចដែលបានបញ្ជាក់នៅក្នុងវេទិកាលើកកម្ពស់សិទ្ធិស្ត្រី ដែលត្រូវបានរៀបចំឡើងជារៀងរាល់ខែនៅក្នុងស្រុកអន្លង់វែងដែរ ស្ត្រីបានបំពេញនូវកាតព្វកិច្ចសំខាន់ៗចំនួន៣របស់ខ្លួន រួមមាន៖ ការធ្វើចម្ការដើម្បីស្ទាក់ខ្មាំងដែលចូលមក ការដឹកជញ្ជូនគ្រឿងសព្វាវុធទៅកាន់សមរភូមិមុខ និងការបម្រើការជាពេទ្យទាហានដែលពាក់ព័ន្ធទៅនឹងការសែង និងព្យាបាលអ្នករបួសពីសមរភូមិមុខ។ ជាពិសេស ស្ត្រីក៏ត្រូវផលិតស្បៀងអាហារដោយខ្លួនឯងដែរ ជាជាងពឹងផ្អែកទាំងស្រុងទៅលើរបបអាហារដែលផ្តល់ដោយ ឈិត ជឿន ហៅតាម៉ុក ដែលជាមេទ័ពនៅក្នុងតំបន់។ ដោយសារកត្តានេះហើយ កងកម្លាំងខ្មែរក្រហមអាចធានាបានថា សង្គ្រាមទ័ពព្រៃរបស់ខ្លួនអាចបន្តដោយឥតស្រាកស្រាន្តក្នុងរយៈពេលជាច្រើនឆ្នាំទៅមុខទៀត។

# ស្ត្រីនៅក្នុងកង
# ធ្វើចម្រូង និងកងដឹកជញ្ជូន



យ៉ន រ៉ែន

គា និងប្តីពិការរបស់ខ្លួនបានចាប់ផ្តើមរស់នៅក្នុងស្រុកអន្លង់វែងនៅឆ្នាំ១៩៩៨។ ក្រោយមក គា បាន ធ្វើការនៅក្នុងកងផលិតចម្រូង។ សេង បានបន្ថែមទៀតថា ការធ្វើចម្រូងមិនធ្វើឲ្យខ្លួនចំណាយពេល ពេញមួយថ្ងៃទេ។ បន្ទាប់ពីស្ត្រីម្នាក់នៅក្នុងគ្រួសារមួយផលិតចម្រូងបាន១០០ដើម ក្នុងមួយថ្ងៃ ស្ត្រីម្នាក់ៗអាច បញ្ចប់ការងាររបស់ខ្លួនសម្រាប់ថ្ងៃនោះហើយ បន្ទាប់មកខ្លួនអាចមើលថែរក្សាកូនរបស់ខ្លួន ធ្វើកិច្ចការនៅតាម ស្រែចម្ការដើម្បីផ្គត់ផ្គង់ក្រុមគ្រួសាររបស់ខ្លួន ហើយកាត់ឫស្សីបន្ថែមទៀតនៅលើកំពូលភ្នំដងរែកដើម្បីបំពេញ តាមផែនការផលិតចម្រូងនាថ្ងៃបន្ទាប់។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីជាច្រើនដូចជា សេង ជាដើម មាន ករណីលើកលែងដែរ ហើយតម្រូវឲ្យធ្វើការឆ្ងាយពីផ្ទះនៅតាមបណ្តាសមរភូមិមុខមួយចំនួន។

នៅពេលសួរថា តើចម្រូងនោះពិតជាមានប្រសិទ្ធភាពក្នុងការរារាំងសត្រូវមិនឲ្យជ្រៀតចូលនៅក្នុងមូលដ្ឋានរបស់ខ្លួនដែរឬទេ ? អ៊ិន ខុម បាននិយាយថា ចម្រូងនោះមិនអាចការពារបានទេ ប៉ុន្តែចម្រូងទាំងអស់នោះអាចធ្វើឲ្យការរុលចូលទៅមុខរបស់សត្រូវមានភាពយឺតយ៉ាវ ខណៈដែលចម្រូងអាចធ្វើឲ្យហូរឈាមយ៉ាងខ្លាំង ហើយចម្រូងក៏មានជ្រលក់ថ្នាំពិសដែរ។ ការជីកអន្លង់ ហើយដាំចម្រូងទាំងអស់នោះនៅបាតខាងក្រោមអាចសម្លាប់អ្នកណាដែលធ្លាក់ចូលទៅក្នុងអន្លង់នោះ។ ខុម បាននិយាយថា អង្គភាពរបស់គាត់មានសមាជិកចំនួន៣០នាក់។ ការធ្វើឲ្យរបួស ការធ្វើឲ្យពិការ និងការសម្លាប់សត្រូវដោយប្រើចម្រូងមិនសូវមានប្រសិទ្ធភាពដូចគ្រាប់កាំភ្លើងទេ។ ការងាររបស់ស្ត្រីក្នុងការផលិតចម្រូងនោះមានតម្លៃយ៉ាងខ្លាំង ហើយទទួលបានការកោតសរសើរថែមទៀត ដូចដែលបង្ហាញតាមរយៈស្តូបស្ត្រីទូលចម្រូងដែលសាងសង់នៅលើកំពូលភ្នំដងរែក។ ទីតាំងនៃស្តូបនោះ គឺជាកន្លែងគោរពបូជា ដើម្បីបន់ស្រន់ឲ្យមានសុខសុវត្ថិភាព និងសំណាងល្អនៅក្នុងកាលៈទេសៈដែលលំបាក។

ខុម បានធ្វើការជាមួយកងដឹកជញ្ជូននេះ ដែលតម្រូវឲ្យគាត់ដើរថ្មើរជើងពី ៤០ទៅ៥០គីឡូម៉ែត្រពីទីរួមស្រុកអន្លង់វែងបច្ចុប្បន្ន។ បទពិសោធន៍របស់គាត់មានភាពប្រហាក់ប្រហែលទៅនឹង ខុម និង យី ជា ដែលមានអាយុ៦៦ និង ហ៊ុយ យាន ដែលមានអាយុ៦២ឆ្នាំដែរ សុទ្ធសឹងមានបទពិសោធន៍ធ្វើការនៅក្នុងកងដឹកជញ្ជូន។ ជា និង យាន បានអះអាងថា ការសែងគ្រាប់ និងសម្ភារធ្វើសង្គ្រាមផ្សេងៗទៀតទៅកាន់សមរភូមិមុខ ត្រូវបានធ្វើឡើងពី៤ទៅ៥ដងក្នុងមួយខែ អ្នកទាំងពីរបានចំណាយពេលជាច្រើនថ្ងៃដើរឆ្លងកាត់ភ្នំ និងព្រៃ ដើម្បីទៅដល់គោលដៅ។

ស្ត្រីទាំងឡាយបាននិយាយស្រដៀងគ្នាថា ខណៈដែលខ្លួនអាចទទួលរងនូវការវាយប្រហារពីកងទ័ពខ្លួនក៏ភ័យខ្លាចចំពោះការរំលោភ ឬការវាយធ្វើបាបដែរ។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីនៅតែមានភាពប្រុងប្រយ័ត្នអំពីបញ្ហានេះ ហើយមិនហ៊ានចេញពីកងរបស់ខ្លួនឡើយ។ សុគន្ធ បាននិយាយថា គាត់ពិតជាចង់វិលត្រឡប់ទៅស្រុកភូមិវិញណាស់។ ប៉ុន្តែខ្លួនខ្លាចវង្វេងនៅក្នុងព្រៃ ហើយអាចនឹងត្រូវបានចាប់រំលោភ។ ដូចអ្នកផ្សេងៗទៀតដែរ សុគន្ធ បានតស៊ូជម្នះដើម្បីឲ្យបានរស់រានមានជីវិតក្នុងអំឡុងពេលនោះ។

ស្ត្រីនៅក្នុងកងដឹកជញ្ជូន បានជួបប្រទះនូវបញ្ហាប្រឈមជាច្រើនចំពោះសុខភាពរបស់ខ្លួន សូម្បីតែរហូតមកដល់បច្ចុប្បន្ន។ ស្ត្រីម្នាក់ៗ ត្រូវបានតម្រូវឲ្យសែងគ្រាប់ធ្ងន់ៗ។ ឧទាហរណ៍ ជារៀងរាល់ពេល ខ្លួនត្រូវសែងគ្រាប់បេ៤០ចំនួន៧គ្រាប់ អង្ករ អាហារ ថ្នាំង និងសម្លៀកបំពាក់ផ្សេងៗទៅកាន់សមរភូមិមុខ។ ការធ្វើដំណើរនោះត្រូវចំណាយពេលជាច្រើនថ្ងៃ ទម្រាំទៅដល់គោលដៅ។ យឹម ផល ដែលមានអាយុ៦៩ឆ្នាំ បាននិយាយថា ខ្លួនបានរស់នៅជាមួយនឹងជំងឺរ៉ាំរ៉ៃជាច្រើនទាំងផ្នែករាងកាយ និងស្មារតី ដោយសារតែការងារទាំងអស់នោះ។ សុខភាពរបស់ខ្លួនក៏បានចុះទ្រុឌទ្រោម ដោយសារតែគាត់បានផឹកទឹកដែលកងទ័ពវៀតណាមបានដាក់ថ្នាំបំពុល។

# ពេទ្យទាហាន



ហ៊ុយ យាន

វង់ រឿន ពេទ្យទាហានខ្មែរក្រហមនៅក្នុងស្រុកអន្លង់វែង ដែលមានអាយុ៦៥ឆ្នាំ បាននិយាយថា៖

*“ការព្យាបាលអ្នកជំងឺម្នាក់ៗ គឺផុសចេញពីទឹកចិត្ត មិនមែនផុសចេញពីរឿងនយោបាយទេ។ ក្នុងនាមជាគ្រូពេទ្យម្នាក់ អាទិភាពសំខាន់បំផុតរបស់យើង គឺត្រូវសង្គ្រោះជីវិតមនុស្ស។”*

ភារកិច្ចជាពេទ្យទាហាន បានបង្កនូវបញ្ហាប្រឈមជាច្រើនចំពោះស្ត្រីដែលទទួលបានការបណ្តុះបណ្តាលផ្នែកពេទ្យរយៈពេលខ្លី ហើយចាប់ផ្តើមប្រើប្រាស់ជំនាញពេទ្យនេះភ្លាមៗតែម្តង។ ទោះបីជាយ៉ាងណាក៏ដោយ ស្ត្រីមួយចំនួនដែលបានផ្តល់បទសម្ភាសន៍ បានទទួលការអប់រំផ្នែកវេជ្ជសាស្ត្រពីប្រទេសចិន ដោយប្រើប្រាស់ការបណ្តុះបណ្តាលនេះនៅក្នុងអំឡុងពេល ឬបន្ទាប់ពីរបបខ្មែរក្រហម។ បើពិនិត្យមើលពីចំនួនដ៏តិចតួចនៃអ្នកដែលមានអាជីពផ្នែកនេះ ចំនួនកើនឡើងនៃមនុស្សដែលធ្លាក់ខ្លួនឈឺ និងរបួសពីសមរភូមិ ក្រុមគ្រូពេទ្យទាហានដែលមានការបណ្តុះបណ្តាលតិចតួចបានក្លាយទៅជាទីបង្អែកដ៏សំខាន់។

មីន លន់ អាយុ៦៨ឆ្នាំ, យ៉ន រ៉ន អាយុ៤៩ឆ្នាំ និង ជា ផល អាយុ៥២ឆ្នាំ បាននិយាយស្រដៀងគ្នាដែរ ទាក់ទងទៅនឹងការបណ្តុះបណ្តាលជំនាញពេទ្យដែលនៅមានកម្រិត មុនពេលដែលទទួលភារកិច្ចព្យាបាលអ្នកជំងឺ។ លន់ បាននិយាយថា ការបណ្តុះបណ្តាលមានរយៈពេលពី២ទៅ៣ខែប៉ុណ្ណោះ។ លន់ បានចាប់ផ្តើមព្យាបាលអ្នករបួសពីសមរភូមិ ខណៈដែលចំនួនអ្នករបួសបានកើនឡើងយ៉ាងច្រើន ដោយសារតែការប៉ះទង្គិចគ្នាយ៉ាងខ្លាំងក្លាជាមួយកងទ័ពវៀតណាមនៅតាមបណ្តោយព្រំដែនក្នុងអំឡុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)។ ផល និង រ៉ន បានទទួលស្គាល់ថា ខ្លួនមិនទទួលបានការបណ្តុះបណ្តាលផ្នែកវេជ្ជសាស្ត្រឲ្យបានត្រឹមត្រូវនោះទេ ហើយបានចូលរួមនៅក្នុងការព្យាបាលជំងឺនេះដោយធ្វើការទស្សន៍ទាយ ថាតើត្រូវផ្តល់នូវការជួយសង្គ្រោះ ឬក៏ដោះស្រាយស្ថានភាពរបួសដោយវិធីណា។ ផល ខ្លួនឯងគ្រាន់តែជានីរសារឃុំប៉ុណ្ណោះមុនពេលដែលខ្លួនចូលរួមក្នុងអង្គភាពពេទ្យ។

ក្នុងចំណោមក្រុមគ្រូពេទ្យដែលមានគ្នាចំនួន២៧នាក់ ក្នុងនោះ១៧នាក់គឺជាស្ត្រី ផល បានចងចាំថាមានវេជ្ជបណ្ឌិតមួយចំនួនតូចដែរ ដែលអាចធ្វើការវះកាត់ ឬកាត់អវយវៈដើម្បីសង្គ្រោះជីវិតមនុស្ស។ អ្វីដែលផល ចងចាំបំផុតនោះ គឺ មានមនុស្សជាច្រើនបានស្លាប់នៅក្នុងចន្លោះឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៩។ វៀន ដែលបច្ចុប្បន្នរស់នៅក្នុងស្រុកអន្លង់វែង ស្ថិតក្នុងចំណោមវេជ្ជបណ្ឌិតជំនាញផ្នែកវះកាត់នេះ បានចំណាយពេល៥ឆ្នាំនៅក្នុងប្រទេសចិន ដើម្បីសិក្សាផ្នែកវេជ្ជសាស្ត្រ ដោយមានជំនាញខាងវះកាត់។ វៀន និងប្តីរបស់ខ្លួនដែលជាគ្រូពេទ្យវះកាត់ដែរនោះ បាននិយាយនៅក្នុងបទសម្ភាសន៍ថា៖

> *"យើងជួយសង្គ្រោះជីវិតទាហាន និងប្រជាជនជាច្រើន ប៉ុន្តែអ្នកជំងឺម្នាក់ដែលយើងមិនភ្លេចគាត់សោះ។ ជើងម្ខាងរបស់គាត់ត្រូវមីនជាទម្ងន់ដែលត្រូវការកាត់ជើងនោះចោល។ ប៉ុន្តែខ្ញុំ និងប្តីរបស់ខ្ញុំបានសម្រេចចិត្តថាមិនកាត់ជើងរបស់គាត់ទេ។ យើងបានលាងសម្អាតមុខរបួសនោះជារៀងរាល់ថ្ងៃ។ យើងបានកាត់ផ្នែកដែលធ្ងន់ធ្ងរនៃមុខរបួសនោះចេញ ហើយយកសាច់ភ្លៅរបស់គាត់ទៅប៉ះជំនួសវិញ។ គាត់បានរស់រានមានជីវិត ហើយគាត់អាចដើរបានដូចធម្មតានាពេលបច្ចុប្បន្ន"។*

វៀន ដែលសព្វថ្ងៃនេះនៅប្រកបរបរផ្នែកវេជ្ជសាស្ត្រនៅឡើយនៅក្នុងស្រុកអន្លង់វែងបាននិយាយថា ពេទ្យទាហានប្រឈមនឹងការលំបាកជាច្រើននៅក្នុងសម័យកាលនោះ។ តែទោះជាយ៉ាងណា វៀន បានធ្វើកិច្ចការនេះដោយសារតែទឹកចិត្តអាណិតអាសូរផង និងជាកាតព្វកិច្ចផង ដើម្បីជួយសង្គ្រោះជីវិតមនុស្សក្នុងនាមជាពូជសាសន៍ខ្មែរតែមួយ។ វៀន និងប្តីរបស់គាត់បានធ្វើកិច្ចការនេះយ៉ាងលំបាកនៅឯភ្នំ១០០៣ នៅក្រោមការគ្រប់គ្រងរបស់តាម៉ុក និងបន្តព្យាបាលអ្នកជំងឺ និងអ្នករបួសជាច្រើនដែលបញ្ជូនមកពីសមរភូមិ។ អ្នកទាំងពីរមិនដែលគិតថ្លៃអ្វីទេ សម្រាប់អ្នកជំងឺនៅឯជំរំពើងព្រះ ដែលប្រជាជនកម្ពុជាជាច្រើនបានរត់គេចចេញពីកងទ័ពវៀតណាមដែលបានចូលមកក្នុងប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៩។ អ្នកទាំងពីរបាននិយាយថា កិច្ចការរបស់ខ្លួន គឺកើតឡើងពីសមានចិត្ត និងភាពអាណិតអាសូរចំពោះអ្នកជំងឺ និងអ្នករបួស។ បន្ទុកដ៏ធ្ងន់បែបនេះ បានបង្ហាញឲ្យឃើញថា មនុស្សជាច្រើនគួរតែអាចត្រូវបានបណ្តុះបណ្តាលដើម្បីទប់ទល់ជាមួយស្ថានការណ៍ដ៏ធ្ងន់ធ្ងរនេះ។ វៀន បាននិយាយថាស្ត្រីជាច្រើនដែលរស់នៅសមរភូមិក្រោយត្រូវមើលថែទាំកូនៗរបស់ខ្លួន ខណៈដែលប្តីរបស់ខ្លួនត្រូវបានបញ្ជូនទៅសមរភូមិមុខ។ វៀន បានបើកការបណ្តុះបណ្តាលចំនួនពីរលើក ដោយមានស្ត្រីចំនួន៦០នាក់ចូលរួម។ តែទោះជាយ៉ាងណា វៀន នៅតែទទួលស្គាល់ថា មានការខ្វះខាតយ៉ាងខ្លាំងចំពោះក្រុមគ្រូពេទ្យ និងគិលានុបដ្ឋាយិកា។ អាស្រ័យហេតុនេះហើយ ក្រុមគ្រូពេទ្យដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ គឺចាំបាច់ណាស់ បើទោះបីជាពេលខ្លះអ្នកទាំងអស់នោះមិនអាចបំពេញការងារប្រកបដោយប្រសិទ្ធភាពខ្លាំងក៏ដោយ។

រ៉ែន និងប្តីរបស់គាត់ត្រូវបានបណ្តុះបណ្តាលឲ្យក្លាយជាគ្រូពេទ្យដែរ។ រ៉ែន និងប្តីក៏បាននិយាយនៅក្នុងបទសម្ភាសន៍ដែរថា គាត់ទាំងពីរបានចូលរួមជាមួយខ្មែរក្រហម និងធ្វើកិច្ចការក្នុងចលនានេះនៅតាមតំបន់ព្រៃ។ ស្ត្រីទទួលខុសត្រូវក្នុងការសែងអ្នកស្លាប់ និងរបួសពីសមរភូមិ និងព្យាបាលអ្នករបួស។ រ៉ែន បានរំឭកអំពីបទពិសោធន៍នៃការព្យាបាលអ្នកជំងឺនៅឯភ្នំ១០០១ ហើយក៏ចងចាំដែរថា សុន សេន ដែលជាអតីតរដ្ឋមន្ត្រីក្រសួងការពារជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យ បានទៅសួរសុខទុក្ខអ្នករងរបួសនោះជាញឹកញាប់។ នៅត្រឹមទសវត្សរ៍ឆ្នាំ១៩៨០ ក្រុមគ្រូពេទ្យបានទទួលគ្រឿងបរិក្ខារៈកាត់ និងឧបករណ៍ចាំបាច់ផ្សេងទៀត ដើម្បីព្យាបាលអ្នកជំងឺធ្ងន់ធ្ងរដោយសារគ្រាប់កាំភ្លើង ឬផ្ទុះមីន។



គឹម លី

# អនុសាសន៍

ស្ត្រីទាំងឡាយដែលបានផ្តល់សម្ភាសន៍នេះ បានផ្តល់អនុសាសន៍មួយចំនួន ដើម្បីធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសង្គមរបស់ខ្លួននាពេលបច្ចុប្បន្ន។ បើទោះជាស្ត្រីបានចូលរួមនៅក្នុងបុព្វហេតុបដិវត្តន៍ និងបន្តការលះបង់របស់ខ្លួននៅក្នុងសង្គ្រាមក្រោយរបបប្រល័យពូជសាសន៍ក៏ដោយ ក៏ស្ត្រីជាច្រើននៅតែមានអារម្មណ៍ថាតូចទាបជាងបុរស។ ជាលទ្ធផល ស្ត្រីបានទទួលរងនូវអំពើហិង្សា ឬការបំពារបំពានដោយសារតែបញ្ហាយេនឌ័រ។ អនុសាសន៍មួយចំនួនដើម្បីដោះស្រាយបញ្ហានេះ ៖

ទី១) ស្ត្រីភាគច្រើនបានវាយតម្លៃវេទិកានេះថាជាទម្រង់នៃការអនុវត្តសិទ្ធិរបស់ខ្លួន។ វេទិកានេះបានផ្តល់សិទ្ធិអំណាច និងលើកទឹកចិត្តឲ្យស្ត្រីមានភាពសកម្មក្នុងការអធិប្បាយបែបប្រវត្តិសាស្ត្រ ហើយនៅក្នុងទិដ្ឋភាពសង្គមនយោបាយដែរ។ កត្តានេះអាចបង្កើតឲ្យមានឱកាស ក្នុងការឆ្លើយតបទៅនឹងពាក្យចាស់បុរាណដែលនិយាយថា៖ «ស្ត្រីបង្វិលចង្ក្រានមិនជុំ។»

ទី២) ការអប់រំរបស់ស្ត្រីគួរតែជាដំណោះស្រាយដើម្បីលើកកម្ពស់ឋានៈរបស់ស្ត្រីដែរ។ ស្ត្រីដែលចូលរួមក្នុងវេទិកាបានគូសបញ្ជាក់អំពីសារសំខាន់នៃភាពមិនងាយទ្រុឌទ្រោម និងសមត្ថភាពរបស់ស្ត្រីក្នុងភាពជាឯករាជ្យ។

ទី៣) ស្ត្រីមួយចំនួនក៏បានគូសបញ្ជាក់ថា ការបង្កើតសមាគមស្ត្រីក៏អាចរួមចំណែកយ៉ាងធំធេងចំពោះកិច្ចខិតខំប្រឹងប្រែងដើម្បីគាំពារសិទ្ធិ និងសុខភាពរបស់ខ្លួនដែរ។ ស្ត្រីនៅក្នុងអតីតតំបន់តស៊ូចុងក្រោយរបស់ខ្មែរក្រហមក៏បានឆ្លងកាត់នូវការលំបាកជាច្រើនដូចដែលបានរៀបរាប់ខាងលើ ហើយស័ក្តិសមនឹងទទួលបានបុព្វសិទ្ធិ និងការថែទាំឲ្យបានប្រសើរជាងនេះ។ កិច្ចការនេះក៏អាចនឹងជំរុញឲ្យស្ត្រីទាំងឡាយបន្តចូលរួមយ៉ាងសកម្ម និងធ្វើការដើម្បីសហគមន៍។

# សេចក្តីសន្និដ្ឋាន

ស្ត្រីមួយផ្នែកធំដែលបានចូលរួមក្នុងវេទិកាលើកកម្ពស់សិទ្ធិស្ត្រី បានជ្រើសរើស និងអត្ថាធិប្បាយនូវបទពិសោធន៍រឿងរ៉ាវរបស់ខ្លួន ដោយចាប់ផ្តើមពីរយៈកាលមុនរបបខ្មែរក្រហម។ ស្ត្រីទាំងនោះបានរៀបរាប់អំពីហេតុផលផ្សេងៗគ្នាដែលខ្លួនបានចូលរួម និងលះបង់អាយុជីវិតដើម្បីបដិវត្តន៍។ ក្រោយមក ស្ត្រីទាំងនោះផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយដែលជារឿយៗ គឺឆ្ងាយអំពីភូមិកំណើតរបស់ខ្លួន។ ស្ត្រីជាច្រើនបានសារភាពថាខ្លួនត្រូវតែជម្នះនូវភាពរំជួលចិត្ត និងភាពភ័យខ្លាចជារៀងរាល់ថ្ងៃ។ តែទោះជាយ៉ាងណាក៏ដោយ ស្ត្រីជាច្រើនបានផ្តោតលើក្តីសង្ឃឹមថា នៅពេលដែលសង្គ្រាមផុតរលត់ទៅ ខ្លួននឹងអាចវិលត្រឡប់ទៅស្រុកកំណើតវិញ។ ការគិតបែបនេះ គឺមិនពិតទេ ខណៈដែលការឡើងកាន់អំណាចរបស់ខ្មែរក្រហមបានបង្កើតស្ថានការណ៍មួយដែលធ្ងន់ធ្ងរជាងមុនទៅទៀត។ សុខភាពរបស់ខ្លួនទទួលរងយ៉ាងធ្ងន់ធ្ងរពីការងារលើសកម្លាំង និងភាពអត់ឃ្លាន។ គឹម លី គឺជាឧទាហរណ៍មួយក្នុងចំណោមស្ត្រីជាច្រើន ដែលប្តីរបស់គាត់ត្រូវបានសម្លាប់ ហើយកូនរបស់គាត់បានស្លាប់ដោយសារខ្វះអាហារូបត្ថម្ភ។

ស្ត្រីជាច្រើន បានធ្វើការប្តេជ្ញាចិត្ត និងលះបង់ដើម្បីបដិវត្តន៍ដូចបុរសដែរ ប្រសិនបើមិនលើសពីបុរសទេនោះ នៅក្នុងអំឡុងរបបប្រល័យពូជសាសន៍ និងក្រោយមកនៅក្នុងអំឡុងសង្គ្រាម។ រយៈកាលក្រោយឆ្នាំ១៩៧៩ គឺជាដំណាក់កាលដ៏ធ្ងន់ធ្ងរមួយទៀតសម្រាប់ស្ត្រី ខណៈដែលស្ត្រីទាំងឡាយត្រូវបានផ្តល់ភារកិច្ចឲ្យជួយទ្រទ្រង់ដល់សមរភូមិមុខ និងធានាឲ្យបានរឹងមាំសម្រាប់សមរភូមិក្រោយ។ ស្ត្រីទាំងឡាយត្រូវបានចាត់ឲ្យធ្វើកិច្ចការដែលលំបាកៗជាច្រើន។ ស្ត្រីត្រូវបានចាត់តាំងឲ្យសែងគ្រឿងសព្វាវុធទៅកាន់សមរភូមិមុខ ដែលស្ថិតនៅឯខេត្តសៀមរាប។ ស្ត្រីទាំងឡាយក៏ត្រូវទទួលភារកិច្ចធ្វើចម្រូង ដើម្បីដាក់អន្ទាក់ខ្មាំងដែលចូលមក ក្រៅតែពីកិច្ចការគ្រួសារដូចជា ដាំដំណាំ និងថែរក្សាកូនចៅរបស់ខ្លួន។ នាពេលបច្ចុប្បន្ននេះស្ត្រីនៅតែជួបប្រទះនូវបញ្ហាប្រឈមជាច្រើនរាប់ចាប់តាំងពីសេចក្តីត្រូវការផ្នែកអប់រំ រហូតដល់ការជួយទ្រទ្រង់ដល់ស្ថានភាពសុខភាពធ្ងន់ធ្ងរ និងជំងឺរ៉ាំរ៉ៃ ក្រៅពីទម្រង់នៃការលើកកម្ពស់សិទ្ធិនៅក្នុងវិស័យសង្គម និងនយោបាយ។



(ពីស្ដាំ ទៅ ឆ្វេង)៖
ជុំ ស្មី (កាន់ដៃក្មួយប្រុស)
ជាម និងយោធាខ្មែរក្រហម
នៅក្នុងទឹកដី៤០
(ភូមិដំកង់ ឬពេទ្យដំកង់)
ក្នុងឆ្នាំ១៩៨៦។



កង មិ កំពុងធ្វើម្សៅនំបញ្ចុក នៅជំរំជនភៀសខ្លួន ត្រង់ចំណុច ជប់ម្លូរ នៃទឹកដីថៃ ក្នុងឆ្នាំ១៩៨៨។



(ពីឆ្វេងទៅស្ដាំ)៖ ប៊ុន សុកុល, កូនខៀវ សំផន (ពាក់អាវពណ៌ស) និងនីវសោរ ខៀវ សំផន  ថតនៅខេត្តកោះកុង។



សៅ (កូនកំលោះ) និង
រ៉ុម (កូនក្រមុំ) រៀបការ នៅម្ដុំ
ឃ្លាំងអំបិលចាស់របស់ តាម៉ុក នៅ
ក្បែរបឹងអូរជើក ដែលបច្ចុប្បន្ន
ជាភូមិអូរជើក ឃុំអន្លង់វែង ស្រុក
អន្លង់វែង នៅក្នុងឆ្នាំ១៩៩២។



ពេជ្រ ស្អិត (ប្ដីកូន) ហឿន ហាន (ប្រពន្ធ)
និងពេជ្រ សំណាង (កូន) នៅជំរំភូមិ៤០
លើភ្នំដងរែក ក្នុងឆ្នាំ១៩៩០។



(ពីឆ្វេងទៅស្ដាំ)៖ ឈុន ហុងសេង ដែលជាអតីតប្រធាន
កងពលលេខ៣ និង ប៊ុន សុកុល ថតនៅឆ្នាំ១៩៩០
នៅអន្លង់វែង។



អោម គន្ធា ថតនៅក្នុងទឹកដីថៃ កាលពីឆ្នាំ១៩៨៧ ។



ខឹម អឹង (ទីបី រាប់ពីឆ្វេង) កំពុងតែពិភាក្សានិងមើលផែនទី នៅត្រង់ចំណុចមុំបី ក្នុងឆ្នាំ១៩៩៥។



*ប្រជាជននៅក្នុងភូមិ៨០០ចាស់ បច្ចុប្បន្នបានក្លាយជាភូមិ ទួលសាលា នៃស្រុកអន្លង់វែង។*



*(ពីឆ្វេងទៅស្តាំ)៖ ប៊ិន សុកុល, កូននិងប្រពន្ធ ប៉ុល ពត និង ផេង ស្រីម៉ុច ថតនៅទំនប់ទឹកតាម៉ុក អំឡុងទសវត្សរ៍ឆ្នាំ៩០។*



*(ពីឆ្វេងទៅស្តាំ) រ៉ុម និង គិន ញ៉ ថតរូបនៅលើទំនប់តាម៉ុក ឬទំនប់បឹងអូរជីក អំឡុងពេលកំពុងសាងសង់ក្នុងឆ្នាំ១៩៩៣។ ញ៉ បាននិយាយថា នៅពេលនោះ ប្រជាជនជាច្រើននៅក្នុងស្រុកអន្លង់វែង រួមទាំងខ្ញុំផង បាននាំគ្នាទៅសែងដី និងថ្មនៅក្នុងការដ្ឋានសាងសង់ទំនប់តាម៉ុក។ យើងក៏មានការលំបាក ហើយភាពនឿយហត់ដែរ ប៉ុន្តែរូបថតមួយសន្លឹកនេះពិតជាបង្ហាញនូវក្តីរីករាយ និងភាពស៊ីវិល័យពីព្រោះពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរបានឈានចូលមកដល់។*

**បទសម្ភាសន៍៖**

សាញ់ សុគន្ធ, ផៃម ឡៃ, ឃុយ គា, ជិន សេង, អ៊ិន ខុម, យី ជា, ហ៊ុយ យាន, ឃឹម ផល, វង់ វៀន, អ៊ួន ណម, គឹម លី, មីន លន់, យ៉ន រ៉ន និង ជា ផល នៅក្នុងស្រុកអន្លង់វែង ក្នុងឆ្នាំ២០១៩។

គម្រោងនិងរបាយការណ៍នេះទទួលបានជំនួយឧបត្ថម្ភពី
**ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ** (USAID)

រក្សាសិទ្ធិឆ្នាំ២០២៣ ដោយ**មជ្ឈមណ្ឌលឯកសារកម្ពុជា**

រក្សាសិទ្ធិគ្រប់យ៉ាង។ មិនមានផ្នែកណាមួយនៃរបាយការណ៍នេះត្រូវបាន បោះពុម្ពឡើងវិញ ឬប្រើប្រាស់ ក្នុងទម្រង់ ឬក្នុងមធ្យោបាយណាមួយឡើយ រួមមានដូចជា ការថតចម្លង ការកត់ត្រាទុក ឬការថតទុកនៅក្នុងប្រព័ន្ធផ្ទុកព័ត៌មានផ្សេងៗទៀត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកបោះពុម្ពបានឡើយ។

**ការអះអាង៖** ការបោះពុម្ពផ្សាយនេះទទួលបានជំនួយហិរញ្ញប្បទានពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ។ មតិយោបល់ ការរកឃើញ និងសេចក្តីសន្និដ្ឋានដែលមាននៅក្នុងឯកសារនេះគឺជារបស់អ្នកនិពន្ធ ហើយមិនឆ្លុះបញ្ចាំងអំពីមតិយោបល់របស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិឡើយ។ ទស្សនៈដែលបានបង្ហាញនៅក្នុងសៀវភៅនេះគឺជាទស្សនៈរបស់អ្នកនិពន្ធតែប៉ុណ្ណោះ។

រូបថតដោយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៃបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

# អំពីមជ្ឈមណ្ឌលឯកសារកម្ពុជា

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៥ បន្ទាប់ពីសភាសហរដ្ឋអាមេរិកអនុម័តឲ្យមានច្បាប់ស្តីពីយុត្តិធម៌សម្រាប់អំពើប្រល័យពូជសាសន៍ នៅក្នុងខែមេសា ឆ្នាំ១៩៩៤ ដែលចុះហត្ថលេខាជាធរមានដោយប្រធានាធិបតី ឃ្លីនតុន។ រាជរដ្ឋាភិបាលកម្ពុជា បានគាំទ្រមជ្ឈមណ្ឌលឯកសារកម្ពុជាជាផ្លូវការ។ មជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលបានការកោតសរសើរ និងពានរង្វាន់ជាច្រើនចំពោះកិច្ចការរបស់ខ្លួន ក្នុងការគាំទ្រឲ្យមានការចងចាំនិងយុត្តិធម៌សម្រាប់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ នៅក្នុងឆ្នាំ ២០១៧ មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានពានរង្វាន់សិទ្ធិមនុស្ស ជូឌិត លី ស្ត្រូណាច់ ពីមជ្ឈមណ្ឌលយុត្តិធម៌និងការទទួលខុសត្រូវ។ នៅក្នុងឆ្នាំដដែល ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ទ្រង់ព្រះរាជទានគ្រឿងឥស្សរយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ធិបឌិន្ទ ដល់លោក ឆាំង យុ ជាការទទួលស្គាល់ស្នាដៃដ៏ល្បីល្បាញរបស់លោកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងឆ្នាំ ២០១៨ មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ជាម្ចាស់ពានរង្វាន់ រ៉ាម៉ុន ម៉ាកសៃ សៃ ដែលត្រូវបានចាត់ទុកថាជាពានរង្វាន់ណូបែលអាស៊ី ក្នុងការថែរក្សាការចងចាំជាប្រវត្តិសាស្ត្រដើម្បីការព្យាបាលរបួសផ្លូវចិត្ត និងយុត្តិធម៌។




ខ្សែព្រំប្រទល់ប្រទេសមិនមានចាត់ទុកជាផ្លូវការ។ *The delineation of international boundaries should not be considered authoritative. Map prepared by Geography Department. 20.08.02.*

| ARCHITECT: DAEWHA KANG DESIGN | DRAWING TITLE: SAMDECH PICHEY SENA TRAILS | KEY: |
|---|---|---|
| DATE: 25.01.2022 | PROJECT: ANLONG VENG MASTERLAN | —— APPROVED ROADS<br>- - - PROPOSED ROADS |

មជ្ឈមណ្ឌលឯកសារកម្ពុជា